**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ....៩៦...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រើប្រាស់គណនី

## ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ នឹងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- បានឃើញសេចក្តីជូនដំណឹងលេខ ១៣១២ សជណ.សរ ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ២០០៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញប្រកាសរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៤ ស្តីពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីបែបបទនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

- ចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៨
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## សម្រេច

**មាត្រា ១ .-** អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រើប្រាស់ថវិកាគណនី " ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ" ដែលត្រូវបានបង្កើតឡើងតាមមាត្រា ៨៣ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ លើមុខសញ្ញាចំណាយសំរាប់ការទូទាត់ប្រាក់សំណងបន្ថែមជូនប្រជារាស្ត្រដែលទទួលរងនូវផលប៉ះពាល់ដោយសារគំរោងការស្តារឡើងវិញកំណាត់ផ្លូវជាតិលេខ ១ ភ្នំពេញ-អ្នកលឿង ក្នុងដំណាក់កាលទី ១, ទី ២ និងទី ៣ សរុបចំនួន ***១.៨០៤.០២៥,៧០ ដុល្លារអាមេរិក*** ( មួយលាន ប្រាំបីរយបួនពាន់ ម្ភៃប្រាំដុល្លារអាមេរិក និងចិតសិបសេន) ស្មើនឹងប្រជាពលរដ្ឋសរុបចំនួន ៣.៧៧០ គ្រួសារ ក្រោមហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួង-ស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ឧសភា ឆ្នាំ ២០០៨*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

***ចំលងជូន:***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- ដូចក្នុងមាត្រា ២
- ឯកសារ-កាលប្បវត្តិ